MAFF

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៥.៥.៤.... ប្រក.កសក

# ប្រកាស

## ស្តីពី

## ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពង់ចាម

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ

## សម្រេច

**ប្រការ ១.-**

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តកំពង់ចាម សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តភាពតាមលក្ខណៈសហគមន៍ព្រៃឈើ ដែលមានទីតាំងស្ថិតក្នុងផ្នែករដ្ឋបាលព្រៃឈើមេមត់ នៃខណ្ឌរដ្ឋបាលព្រៃឈើកំពង់ចាម ។

**ប្រការ ២.-**

ការបង្កើតតំបន់ព្រៃសហគមន៍ក្នុងគោលបំណង :

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្ស និង អភិវឌ្ឍព្រៃសហគមន៍ឱ្យមាននិរន្តភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើ ជាលក្ខណៈប្រពៃណី សម្រាប់ការរស់នៅ ទំនៀមទម្លាប់ និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមសក្តានុពល និង លទ្ធភាពធនធានព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ៣.-**

តំបន់ព្រៃសហគមន៍ក្នុងខេត្តកំពង់ចាមនៃប្រកាសនេះមាន ០៥ សហគមន៍ព្រៃឈើ ចែកចេញជា ០៥ កន្លែង ដែលមានផ្ទៃដីសរុបចំនួន ១.៧៨៣ (មួយពាន់ប្រាំពីររយប៉ែតសិបបី) ហិកតា ដូចមានក្នុងផែនទីទីតាំងព្រៃសហគមន៍ និងផែនទីសហគមន៍នីមួយៗភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ និង ជាប្រព័ន្ធខ្សែព្រំបិទជិត កំណត់ដោយចំណុចគោល និង និយាមកាដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ ។

**ប្រការ ៤.-**

ដំណើរការរៀបចំ និង ការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើ ក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះត្រូវអនុវត្តតាមនីតិវិធី ដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និង ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។

**ប្រការ ៥.-**

ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

២

៥

ប្រការ ៦._

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយដ្ឋានផែនការនិងស្ថិតិ ប្រធានមន្ទីរកសិកម្មខេត្តកំពង់ចាម និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី...២០...ខែ..សីហា...ឆ្នាំ ..២០១០

រដ្ឋមន្ត្រី

ច័ន្ទ.សារុន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកំពង់ចាម
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

